ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ......១០០៥........អពជ

ថ្ងៃ អង្គារ ០៦កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## កម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចី ឆ្នាំ២០២០

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី៣ ផ្នែកទី៣.១ នៃប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស និងសេចក្តីណែនាំលេខ៧០១៥ អពដ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់ឱ្យនិយោជិតខ្ចី ព្រមទាំងសេចក្តីណែនាំលេខ ១៥១ អពដ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចី ឆ្នាំ២០២០ ដោយផ្អែកលើការគណនាមធ្យមភាគនៃមធ្យមភាគអត្រាការប្រាក់ឱ្យខ្ចីប្រចាំឆ្នាំរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ៨ (ប្រាំបី) ដូចខាងក្រោម÷

- **៨,៩២% ក្នុងមួយឆ្នាំ** ចំពោះប្រាក់រៀល
- **៨,៤៥% ក្នុងមួយឆ្នាំ** ចំពោះប្រាក់ដុល្លារអាមេរិក។

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់បន្ថែមថា អត្រាការប្រាក់ខាងលើនេះប្រើប្រាស់ក្នុងគោលដៅអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់ឱ្យនិយោជិតខ្ចីតែប៉ុណ្ណោះ។ ចំពោះប្រតិបត្តិការខ្ចីប្រាក់ក្នុងចំណោមបុគ្គលទាក់ទិន អត្រាការប្រាក់ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ១១៩៨៦ អពដ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ស្តីពីវិធានការប្រាក់ចំពោះបុគ្គលទាក់ទិន ជាធរមាន។ ដោយឡែក ចំពោះប្រតិបត្តិការខ្ចីប្រាក់ក្នុងចំណោមបុគ្គលមិនទាក់ទិន អត្រាការប្រាក់ត្រូវអនុវត្តតាមប្រតិបត្តិការកម្ចីជាក់ស្តែង ដែលមានចែងក្នុងកិច្ចសន្យានិងឯកសារគាំទ្រច្បាស់លាស់ ដោយមិនអនុវត្តតាមកថាខណ្ឌ៣ ចំណុច ក នៃសេចក្តីណែនាំលេខ ១៥១ អពដ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស ទៀតឡើយ។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh